ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ..............................

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦១
ភ្នំពេញ ថ្ងៃទី២២ ខែមិនា ឆ្នាំ២០១៨

**សូមគោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ នៃគ.ជ.ប.ជ**
**ឯកឧត្តម អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

**ជាទីគោរព**

**កម្មវត្ថុ៖** របាយការណ៍ស្ដីពីលទ្ធផលនៃកិច្ចប្រជុំដើម្បីពិនិត្យ និងឆ្លងសេចក្ដីព្រាងច្បាប់ស្ដីពី " **ការពពោះជំនួស** " នៅពីថ្ងៃទី២២ ខែមិនា ឆ្នាំ២០១៨។

**យោង** ៖ - លិខិតអញ្ជើញរបស់ក្រសួងកិច្ចការនារី លេខ៤៩៨ក.ក.ន ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១៨។
- យោងតាមចំណារអនុញ្ញាតរបស់ **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១៨។

តាមរយៈ៖ ឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គជបជ

តបតាមកម្មវត្ថុនិងយោងខាងលើ នាងខ្ញុំ សូមគោរពរាយការណ៍ជូន **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និងឯកឧត្តម** ស្ដីពីលទ្ធផលនៃកិច្ចប្រជុំដើម្បីពិនិត្យ និងឆ្លងសេចក្ដីព្រាងច្បាប់ស្ដីពី " **ការពពោះជំនួស**" ដែលបានប្រព្រឹត្តទៅនៅសាលប្រជុំក្រសួងយុត្តិធម៌ កាលពីថ្ងៃទី២២ ខែមិនា ឆ្នាំ២០១៨ ពីម៉ោង៨ព្រឹក រហូតដល់ម៉ោង៦រសៀល។ កិច្ចប្រជុំពិភាក្សាដឹកនាំដោយ លោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមានសមាជិកសមាជិកាអង្គប្រជុំចំនួន ២០រូប តំណាងឲ្យក្រសួងយុត្តិធម៌ លោកទីប្រឹក្សាក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងសុខាភិបាល ក្រសួងសហប្រតិបត្តិការអន្តរជាតិ និងការបរទេស ក្រសួងសង្គមកិច្ច យុវនីតិសម្បទា ក្រសួងកិច្ចការនារី និងអគ្គលេខាធិការដ្ឋានគជបជ។

អង្គប្រជុំបានពិនិត្យទៅលើ សេចក្ដីព្រាងច្បាប់ស្ដីពី " **ការពពោះជំនួស**" ដែលរៀបចំដោយក្រសួងកិច្ចការយុត្តិធម៌ ដែលមាន៩ជំពូក និង៦២មាត្រា។ ការជជែកពិភាក្សា បានសម្រេចដូចតទៅ៖

**ជំពូកទី១ បទបញ្ញត្តិទូទៅ** មាន៥មាត្រា -

មាត្រា១ គោលដៅ

មាត្រា២ គោលបំណង

មាត្រា៣ វិសាលភាព - គឺក្តោបតែនៅក្នុងអធិបតេយ្យនៃដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

(ចំពោះករណីដែលលើកដោយនាងខ្ញុំអំពីបញ្ហាដែលបានលឺ ស្តីពីការដែលមានស្ត្រីខ្មែរបាន ចេញទៅធ្វើការពពោះនៅក្នុងប្រទេសថៃ ស្នាក់នៅក្នុងវីឡា ពេលបង្កើតកូនរួចទុកកូន ឲ្យថៅកែ ហើយទទួលបានប្រាក់៨០០០$ ដែលថៅកែជាជនសង្ស័យអាចស្ថិតក្នុងករណី ជួញដូរទារកនោះ លោកជំទាវ ចាន់ សុធារី រដ្ឋលេខាធិការក្រសួងយុត្តិធម៌បានឲ្យយោបល់ថា ត្រូវរៀបចំឲ្យមាននីតិអន្តរជាតិឯកជនសម្រាប់បញ្ហានេះ)

មាត្រា៤ និយមន័យ - លុបភាសាអង់គ្លេសដែលបញ្ជាក់ ដោយក្រសួងសុខាភិបាលបញ្ជាក់ថា ភាសា ខ្មែរមានន័យគ្រប់គ្រាន់ និងលុបពាក្យ (ក្រៅអូវែមនុស្ស)

មាត្រា៥ គោលការណ៍ជាមូលដ្ឋាន - ចំនុចទី៤ គំនូសទី២ បន្ថែមពាក្យ សុខភាពផ្លូវចិត្ត និងផ្លូវកាយ លុបពាក្យ ផ្លូវអារម្មណ៍

**ជំពូកទី២៖** រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច របស់គណៈកម្មាការជំនាញ និងការិយាល័យទទួលពាក្យសុំ (បានកែមកជា **ស្ថាប័នមានសមត្ថកិច្ច**) មាន៦មាត្រា

មាត្រា៦ គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

(ជាគណៈកម្មាធិការដែលដឹកនាំដោយក្រសួងកិច្ចការនារី និងមានក្រសួងជំនាញ និងស្ថាប័នដទៃទៀតចូលរួមជាពិសេសក្រសួងសុខាភិបាល ដែលសមាសភាពនិងត្រូវកំណត់ដោយ អនុក្រឹត្យ)

មាត្រា៧ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

មាត្រា៨ គណៈកម្មាការជំនាញ

(ក្រសួងសុខាភិបាលនិងបង្កើតគណៈកម្មាការជំនាញ ដែលសមាសភាពកំណត់ដោយ ក្រសួងសុខាភិបាល និងលុបគណៈកម្មាធិការនៃការផ្សាំកោសិកា មកបង្កើតគណៈកម្មាធិការ ដែលមានការងារពពោះចូលដែរ)

មាត្រា៩ តួនាទី និងភារកិច្ចរបស់គណៈការជំនាញ

មាត្រា១០ ការិយាល័យទទួលពាក្យសុំ

(ដំបូងការិយាល័យដាក់នៅក្រសួងសុខាភិបាល ប៉ុន្តែដោយសារការស្នើសុំពីក្រសួងសុខាភិបាល បានប្តូរមកដាក់ទីតាំងនៅក្រសួងកិច្ចការនារីវិញ)

មាត្រា ១១ តួនាទី និងភារកិច្ច របស់ការិយាល័យទទួលពាក្យសុំ

(មានក្រសួងសុខាភិបាលជាសមាជិក ។ អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល មានអាជ្ញាបណ្ណ ឯ អ្នកវិជ្ជាជីវៈសុខាភិបាល ជាពេទ្យក្របខណ្ឌ មានប្រកបរបរក្រៅម៉ោង)

**ជំពូកទី ៣៖ លក្ខខណ្ឌ និងនីតិវិធីនៃការពពោះជំនួស** មាន៤ផ្នែក និង២១មាត្រា

**ផ្នែកទី ១៖** លក្ខខ័ណ្ឌនៃការពពោះជំនួស

(

| **អ្នកស្នើសុំ** | | **អ្នកពពោះ** |
|---|---|---|
| ស្រី | | ok |
| ប្រុស | | ok |
| **អ្នកបរិច្ចាក** | | |
| ប្រុស | | ok |
| ស្រី | | មិនអនុញ្ញាត |

ការផ្សាំដោយយកមេជីវិតពីអ្នកបរិច្ចាកទាំងពីរ គឺមិនអាចរាប់បញ្ចូលជាករណី Surrogacy បានទេ ដោយសារមិនមានទំនាក់ទំនងហ្សែននិងអ្នកស្នើសុំ ។ ចំនុចនេះគឺជាគោលការណ៍ដែលជជែកគ្នា នៅ Dublin ឆ្នាំ២០១៧ តែកម្ពុជាមិនបានចុះហត្ថលេខាទេ ។ - ពីក្រសួងយុត្តិធម៌)

មាត្រា ១២ ការបង្កើតអំប្រីយ៉ុង

មាត្រា ១៣ លក្ខខណ្ឌរបស់ប្តីប្រពន្ធដែលដាក់ពាក្យសុំ

(លុបមិនមែនជាជនជាតិខ្មែរ ដូរទៅជា មិនមានសញ្ជាតិខ្មែរ)

មាត្រា ១៤ លក្ខខណ្ឌរបស់អ្នកបរិច្ចាគមេជីវិត

មាត្រា ១៥ លក្ខខណ្ឌរបស់អ្នកពពោះជំនួស

(ចំនុចទី២ ត្រូវមានអាយុចាប់ពី ១៨ (ដប់ប្រាំបី)ឆ្នាំ ដល់៤០ (សែសិប)ឆ្នាំ ដូរជាដល់ ៣៥(សាមសិបប្រាំឆ្នាំ) - ឥណ្ឌា២៥ឆ្នាំ ដល់៣៥ឆ្នាំ, អូស្ត្រាលី ២៥ឆ្នាំ ឡើងទៅ)

**ផ្នែកទី២៖** កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

មាត្រា ១៦ និយមន័យនៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

មាត្រា ១៧ ទម្រង់នៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

មាត្រា ១៨ ខ្លឹមសារនៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

មាត្រា ១៩ ការរំលាយកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

មាត្រា ២០ បញ្ញត្តិពិសេសអំពីការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទាក់ទង នឹងការពពោះជំនួស

មាត្រា ២១ ការបញ្ចប់កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

**ផ្នែកទី ៣៖** នីតិវិធីនៃការដាក់ពាក្យសុំពពោះជំនួស

មាត្រា ២២ របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

(ចំនុចទី១ ប្តូរការិយាល័យទទួលពាក្យសុំនៃក្រសួងសុខាភិបាល មកជាក្រសួងកិច្ចការនារី)

មាត្រា ២៣ ឯកសារភ្ជាប់ជាមួយពាក្យសុំពពោះជំនួស

(ចំនុចទី១ ឃ ប្តូរមិនមែនជាជនជាតិខ្មែរ មកជា មិនមានសញ្ជាតិខ្មែរ)

មាត្រា ២៤ ការប្រគល់ច្បាប់ដើម នៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬឯកសារផ្សេងទៀត

មាត្រា ២៥ ការពិនិត្យពាក្យសុំពពោះជំនួសដោយការិយាល័យទទួលពាក្យសុំ

មាត្រា ២៦ លិខិតបង្គាប់អោយកែតម្រូវ និងលិខិតលើកចោល

មាត្រា ២៧ ការបញ្ជូនពាក្យសុំពពោះជំនួស

មាត្រា ២៨ ការពិនិត្យពាក្យសុំពពោះជំនួស និងឯកសារភ្ជាប់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

មាត្រា ២៩ ការពិនិត្យការបញ្ជូនលទ្ធផល និងយោបល់ដោយគណៈកម្មការជំនាញ

មាត្រា ៣០ ការពិនិត្យ និងសម្រេចដោយគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

**ផ្នែកទី ៤៖** នីតិវិធីនៃការដាក់ពាក្យសុំអោយពិនិត្យឡើងវិញ និងការប្តឹងតវ៉ា

មាត្រា ៣១ ពាក្យសុំអោយពិនិត្យឡើងវិញ ចំពោះការលើកចោលពាក្យសុំពពោះជំនួសរបស់ការិយាល័យទទួលពាក្យសុំ

មាត្រា ៣២ ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចទាក់ទងទៅនឹងការពពោះជំនួស របស់គណៈកម្មការជាតិគ្រប់គ្រងការពពោះជំនួស

**ជំពូកទី ៤៖ ការអនុវត្តការពពោះជំនួស និងការតាមដានក្រោយពីការដាក់អំប្រ៊ីយ៉ុង**

មាត្រា ៣៣ ការជ្រើសរើសកន្លែងផ្តល់បច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើអោយការពពោះជំនួស

មាត្រា ៣៤ ការផ្តល់សេវាកម្មលើបច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើអោយការពពោះជំនួស

(ចំនុចទី២
- បន្ថែមពាក្យ អំប្រ៊ីយ៉ុងនោះ ត្រូវបង្កើតឡើងដោយមិនទាក់ទងនឹងការជ្រើសរើសភេទ លើកលែងតែក្នុងករណីអាចមានជំងឺ។
- ចំពោះករណីអនុញ្ញាតតែអំប្រ៊ីយ៉ុងតែមួយគត់ ព្រោះជារឿងស្ម័គ្រចិត្ត និងការពារផលប្រយោជន៍ស្ត្រីពពោះ ។ )

មាត្រា ៣៥ ការរក្សាទុក ការប្រើប្រាស់ និងការបញ្ចប់អត្ថិភាពនៃមេជីវិត និងអំប្រ៊ីយ៉ុង

មាត្រា ៣៦ ការតាមដាន ការប្រើប្រាស់បច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើអោយការពពោះជំនួស

មាត្រា ៣៧ ការរំលូតកូន

**ជំពូកទី ៥៖ ការសម្រេចអំពីបុត្តភាព**

មាត្រា ៣៨ មាតុភាព

មាត្រា ៣៩ ការសន្មតបិតុភាព

មាត្រា ៤០ ករណីយកិច្ចនៃការចុះបញ្ជីកំណើត

**ជំពូកទី ៦៖ សុំកូន**

មាត្រា ៤១ សុំកូនពេញលេញ

(ចំនុចទី៣ បន្ថែម ស្ថានភាពរាងកាយ ស្ថានភាពផ្លូវចិត្ត ។ ចំនុចចាំបាច់ផ្សេងទៀត គឺយោងតាមមាត្រា១០១២ ក្រមរដ្ឋប្បវេណី)

មាត្រា ៤២ សុំកូនពេញលេញ ក្នុងករណីសហព័ទ្ធម្ខាង មិនមែនជាជនជាតិខ្មែរ (ប្តូរមិនមានសញ្ជាតិខ្មែរ)

មាត្រា ៤៣ ស្នំកូនធម្មតា ក្នុងករណីសហព័ទ្ធណាម្ខាងនៃអ្នកដាក់ពាក្យ សុំបានទទួលមរណភាព ក្រោយពេលដាក់ពាក្យសុំកូនពេញលេញ

មាត្រា ៤៤ ស្នុំកូនធម្មតា

(នៅចំនុចទី១ បានបន្ថែមពាក្យ ក្នុងករណីដែលប្តីប្រពន្ធដែលជាអ្នកដាក់ពាក្យសុំពពោះជំនួស ស្ថិតនៅក្នុងនីតិវិធីលែងលះនៅតុលាការ ឬបានលែងលះគ្នា... )

(ឥតព្រមព្រៀង = ចេញសាលក្រម (បណ្តឹង) - ព្រមព្រៀងគ្នា = សេចក្តីសម្រេច (ពាក្យសុំ))

មាត្រា ៤៥ ការចុះបញ្ជី និងការរក្សាការសម្ងាត់នៃស្នុំកូន ដែលកើតមកពីការពពោះជំនួស

មាត្រា ៤៧ សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំដែលកើតមកពីការពពោះជំនួស

**ជំពូកទី ៧៖ ការទទួលខុសត្រូវរបស់អ្នកដាក់ពាក្យសុំពពោះជំនួស**

មាត្រា ៤៨ បន្ទុកចំណាយរបស់អ្នកដាក់ពាក្យសុំពពោះជំនួស

(ចំនុចទី២ ពន្ធដាក់ពាក្យសុំពពោះជំនួស និងសោហ៊ុយផ្សេងៗ ត្រូវកំណត់ដោយប្រកាសរួមក្រសួងបី គឺក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ)

មាត្រា ៤៩ ការទទួលខុសត្រូវ ក្នុងការណីអ្នកដាក់ពាក្យសុំពពោះជំនួសមិនបានដាក់ពាក្យសុំកូន

(ប្តូរ មិនមែនជាជនជាតិខ្មែរ មកជា មិនមានសញ្ជាតិខ្មែរ)

មាត្រា ៥០ ការទទួលខុសត្រូវ ចំពោះការបំពានកិច្ច របស់អ្នកដាក់ពាក្យសុំពពោះជំនួស

**ជំពូកទី ៨៖ ទោសប្បញ្ញត្តិ**

**(ជាបន្ទុកពិនិត្យរបស់ក្រសួង យុត្តិធម៌)**

មាត្រា ៥១ អំពើលក់ ដូរ មេជីវិតញី ឈ្មោល ឬអំប្រ៊ីយ៉ុង

មាត្រា ៥២ ការអោយប្រាក់ វត្ថុមានតម្លៃ ឬផលប្រយោជន៍ដោយមានគោលដៅ

មាត្រា ៥៣ អំពើធ្វើជាអន្តរការី

មាត្រា ៥៤ ការផ្សព្វផ្សាយជាសាធារណៈទាក់ទងនឹងការពពោះជំនួស

មាត្រា ៥៥ ការផ្តល់សេវាពពោះជំនួស ដោយគ្មានឈ្មោះក្នុងបញ្ជី

មាត្រា ៥៦ ការប្រើបច្ចេកវិទ្យាជំនួយការបង្កកំណើត ដោយពុំទាន់មានការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

មាត្រា ៥៧ ការផ្តល់សេវា ដើម្បីអោយជនដទៃធ្វើអាជីវកម្មពពោះជំនួស

មាត្រា ៥៨ អំពើបំពានការប្រើប្រាស់អំប្រ៊ីយ៉ុង និងការជ្រើសរើសភេទ

មាត្រា ៥៩ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

មាត្រា ៦០ ទោសបន្ថែមដែលអនុវត្តចំពោះនីតិបុគ្គល

**ជំពូកទី ៩៖ អវសានប្បញ្ញត្តិ**

**(ជាបន្ទុកពិនិត្យរបស់ក្រសួង យុត្តិធម៌)**

មាត្រា ៦១ អានុភាពនៃបទប្បញ្ញត្តិដែលផ្ទុយនឹងច្បាប់នេះ

មាត្រា ៦២ កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ

ក្រុមប្រឹក្សាអ្នកច្បាប់និងយកច្បាប់នេះទៅប្រជុំផ្ទៃក្នុងក្រុមតូចសិន បើមានយោបល់កែប្រែនិងជម្រាបជូនជាក្រោយ មុនដាក់ជូនទៅគណៈរដ្ឋមន្ត្រីពិនិត្យជារួម។

ការកំណត់ពេលប្រជុំអន្តរក្រសួង មុនដាក់ចូលការពារនៅទីស្តីការគណៈរដ្ឋមន្ត្រី ខាងក្រសួងកិច្ចការនារី និងជម្រាបជូនក្រោយចូលឆ្នាំខ្មែរ។

អាស្រ័យហេតុនេះសូម **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ និងឯកឧត្តមអគ្គលេខាធិការ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ និងឯកឧត្តមអគ្គលេខាធិការ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ ។

**អគ្គលេខាធិការរង**

ង៉ែត_សិរីលក្ខិណា

**ឯកសារជូនភ្ជាប់៖**

- សេចក្តីព្រាងច្បាប់ស្តីពី " ការពពោះជំនួស "

ចម្លងជូន៖

- ការិយាល័យលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គជបជ
- ការិយាល័យឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គលេខាធិការ គជបជ
- លេខាធិការដ្ឋាន គជបជ
- ឯកសារកាលប្បវត្តិ

# សេចក្តីព្រាងច្បាប់

# ស្តីពី

# ការពពោះជំនួស

## មាតិកា

## ជំពូកទី ១៖ បទប្បញ្ញត្តិទូទៅ


មាត្រា ១.- គោលដៅ ..... ១

មាត្រា ២.-គោលបំណង ..... ១

មាត្រា ៣.- វិសាលភាព ..... ១

មាត្រា ៤.- និយមន័យ ..... ១

មាត្រា ៥.-គោលការណ៍ជាមូលដ្ឋាន ..... ២


## ជំពូកទី ២៖ រចនាសម្ព័ន្ធ តួនាទី និង ភារកិច្ច របស់ គណៈកម្មាធិការជាតិ គ្រប់គ្រងការពពោះជំនួស គណៈកម្មការជំនាញ និង ការិយាល័យទទួលពាក្យសុំ


មាត្រា ៦.- គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ..... ៣

មាត្រា ៧.- តួនាទី និងភារកិច្ច របស់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ..... ៣

មាត្រា ៨.- គណៈកម្មការជំនាញ ..... ៤

មាត្រា ៩.-តួនាទី និងភារកិច្ច របស់គណៈកម្មការជំនាញ ..... ៤

មាត្រា ១០.- ការិយាល័យទទួលពាក្យសុំ ..... ៥

មាត្រា ១១.- តួនាទី និងភារកិច្ច របស់ការិយាល័យទទួលពាក្យសុំ ..... ៥


## ជំពូកទី៣៖ លក្ខខណ្ឌ និងនីតិវិធីនៃការពពោះជំនួស

### ផ្នែកទី ១៖ លក្ខខណ្ឌនៃការពពោះជំនួស


មាត្រា ១២.-ការបង្កើតអំប្រ៊ីយ៉ុង ..... ៦

មាត្រា ១៣.- លក្ខខណ្ឌរបស់ប្ដីប្រពន្ធដែលដាក់ពាក្យសុំ ..... ៦

មាត្រា១៤.- លក្ខខណ្ឌរបស់អ្នកបរិច្ចាគមេជីវិត ..... ៧

មាត្រា ១៥.-លក្ខខណ្ឌរបស់អ្នកពពោះជំនួស ..... ៧


### ផ្នែកទី២៖ កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

មាត្រា ១៦.- និយមន័យនៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ........ ៨

មាត្រា ១៧.- ទម្រង់នៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ........ ៨

មាត្រា ១៨.- ខ្លឹមសារនៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ........ ៩

មាត្រា ១៩.- ការរំលាយកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ........ ៩

មាត្រា ២០.- បញ្ញត្តិពិសេសអំពីការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ........ ១០

មាត្រា ២១.- ការបញ្ចប់កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ........ ១០

## ផ្នែកទី ៣៖ នីតិវិធីនៃការដាក់ពាក្យសុំពពោះជំនួស

មាត្រា ២២.- របៀបដាក់ពាក្យសុំ និង ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ ........ ១១

មាត្រា ២៣.- ឯកសារភ្ជាប់ជាមួយពាក្យសុំពពោះជំនួស ........ ១១

មាត្រា ២៤.- ការប្រគល់ច្បាប់ដើមនៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀត ........ ១២

មាត្រា ២៥.- ការពិនិត្យពាក្យសុំពពោះជំនួសដោយការិយាល័យទទួលពាក្យសុំ ........ ១៣

មាត្រា ២៦.- លិខិតបង្គាប់ឲ្យកែតម្រូវ និងលិខិតលើកចោល ........ ១៣

មាត្រា ២៧.- ការបញ្ជូនពាក្យសុំពពោះជំនួស ........ ១៣

មាត្រា២៨.- ការពិនិត្យពាក្យសុំពពោះជំនួស និងឯកសារភ្ជាប់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ........ ១៣

មាត្រា ២៩.- ការពិនិត្យ ការបញ្ជូនលទ្ធផល និងយោបល់ដោយគណៈកម្មការជំនាញ ........ ១៤

មាត្រា ៣០.- ការពិនិត្យ និង សម្រេចដោយគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ........ ១៥

## ផ្នែកទី៤៖ នីតិវិធីនៃការដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ និងការប្តឹងតវ៉ា

មាត្រា ៣១.- ពាក្យសុំឲ្យពិនិត្យឡើងវិញ ចំពោះការលើកចោលពាក្យសុំពពោះជំនួសរបស់ការិយាល័យទទួល ពាក្យសុំ ........ ១៥

មាត្រា ៣២.- ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចទាក់ទងទៅនឹងការពពោះជំនួស របស់គណៈកម្មការជាតិគ្រប់គ្រង ការពពោះជំនួស ........ ១៥

# ជំពូកទី ៤៖ ការអនុវត្តការពពោះជំនួស និងការតាមដានក្រោយពីការដាក់អំប្រ៊ីយ៉ុង

មាត្រា ៣៣.- ការជ្រើសរើសកន្លែងផ្តល់បច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើឲ្យការពពោះជំនួស .................. ១៦

មាត្រា ៣៤.- ការផ្តល់សេវាកម្មលើបច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើឲ្យការពពោះជំនួស.......................... ១៦

មាត្រា ៣៥.- ការរក្សាទុក ការប្រើប្រាស់ និងការបញ្ចប់អត្ថិភាពនៃមេជីវិត និងអំប្រ៊ីយ៉ុង ................................ ១៧

មាត្រា ៣៦.- ការតាមដាន ការប្រើប្រាស់បច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើឲ្យការពពោះជំនួស ................ ១៧

មាត្រា ៣៧.- ការរំលូតកូន ................................................................................................................... ១៧

## ជំពូកទី ៥៖ ការសម្រេចអំពីបុត្តភាព

មាត្រា ៣៨.- មាតុភាព....................................................................................................................... ១៧

មាត្រា ៣៩.- ការសន្មតបិតុភាព.............................................................................................................. ១៧

មាត្រា ៤០.- ករណីយកិច្ចនៃការចុះបញ្ជីកំណើត ..................................................................................... ១៧

## ជំពូកទី ៦៖ សុំកូន

មាត្រា ៤១.- សុំកូនពេញលេញ ............................................................................................................ ១៨

មាត្រា ៤២.- សុំកូនពេញលេញ ក្នុងករណីសហព័ទ្ធម្ខាង មិនមែនជាជនជាតិខ្មែរ .......................................... ១៩

មាត្រា ៤៣.- សុំកូនធម្មតា ក្នុងករណីសហព័ទ្ធណាម្ខាងនៃអ្នកដាក់ពាក្យសុំបានទទួលមរណភាព ក្រោយពេលដាក់ ពាក្យសុំកូនពេញលេញ ........................................................................................................ ១៩

មាត្រា ៤៤.- សុំកូនធម្មតា ................................................................................................................... ១៩

មាត្រា ៤៥.- នីតិវិធីសម្រេចអំពីសុំកូន.................................................................................................... ២០

មាត្រា ៤៦.- ការចុះបញ្ជី និងការរក្សាការសម្ងាត់នៃសុំកូន ដែលកើតមកពីការពពោះជំនួស............................. ២០

មាត្រា ៤៧.- សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំដែលកើតមកពីការពពោះជំនួស........................................ ២០

## ជំពូកទី ៧៖ ការទទួលខុសត្រូវរបស់អ្នកដាក់ពាក្យសុំពពោះជំនួស

មាត្រា ៤៨.- បន្ទុកចំណាយរបស់អ្នកដាក់ពាក្យសុំពពោះជំនួស ................................................................ ២១

មាត្រា ៤៩.- ការទទួលខុសត្រូវ ក្នុងករណីអ្នកដាក់ពាក្យសុំពពោះជំនួសមិនបានដាក់ពាក្យសុំកូន...................... ២១

មាត្រា ៥០.- ការទទួលខុសត្រូវ ចំពោះការបំពានកិច្ច របស់អ្នកដាក់ពាក្យសុំពពោះជំនួស ............................... ២២

## ជំពូកទី ៨៖ ទោសប្បញ្ញត្តិ


មាត្រា ៥១.- អំពើលក់-ដូរ មេជីវិតញី ឈ្មោល ឬអំប្រ៊ីយ៉ុង..........២២

មាត្រា ៥២.- ការឲ្យ ប្រាក់ វត្ថុមានតម្លៃ ឬ ផលប្រយោជន៍ ដោយមានគោលដៅ..........២៣

មាត្រា ៥៣.- អំពើធ្វើជាអន្តរការី..........២៣

មាត្រា ៥៤.- ការផ្សព្វផ្សាយជាសាធារណៈ ទាក់ទងនឹងការពពោះជំនួស..........២៣

មាត្រា ៥៥.- ការផ្តល់សេវាពពោះជំនួស ដោយគ្មានឈ្មោះក្នុងបញ្ជី..........២៤

មាត្រា ៥៦.- ការប្រើបច្ចេកវិទ្យាជំនួយការបង្កកំណើត ដោយពុំទាន់មានការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រង ការពពោះជំនួស..........២៤

មាត្រា ៥៧.- ការផ្តល់សេវា ដើម្បីឲ្យជនដទៃធ្វើអាជីវកម្មពពោះជំនួស..........២៥

មាត្រា ៥៨.- អំពើបំពានការប្រើប្រាស់អំប្រ៊ីយ៉ុង និងការជ្រើសរើសភេទ..........២៦

មាត្រា ៥៩.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល..........២៦

មាត្រា ៦០.- ទោសបន្ថែមដែលអនុវត្តចំពោះនីតិបុគ្គល..........២៦


## ជំពូកទី ៩
## អវសានប្បញ្ញត្តិ


មាត្រា ៦១.- អានុភាពនៃបទប្បញ្ញត្តិដែលផ្ទុយនឹងច្បាប់នេះ..........២៧

មាត្រា ៦២.- កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ..........២៧

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១ –** គោលដៅ

ច្បាប់នេះ មានគោលដៅបញ្ញត្តអំពីលក្ខខណ្ឌ នីតិវិធី និងវិធាននានាដែលពាក់ព័ន្ធទៅនឹងការពពោះជំនួស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ –** គោលបំណង

ច្បាប់នេះ មានគោលបំណង ធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវការពពោះជំនួស ដើម្បីការពារសិទ្ធិរបស់ជនដែលពាក់ព័ន្ធទៅនឹងការពពោះជំនួស ជាពិសេស ស្ត្រី និងកុមារឲ្យបានសមស្របតាមបញ្ញត្តិច្បាប់ និងការពារ ទប់ស្កាត់ មិនឲ្យមានអាជីវកម្មតាមរយៈសេវាពពោះជំនួស ។

**មាត្រា ៣ –** វិសាលភាព

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការពពោះជំនួស ដោយផ្អែកលើពាក្យសុំដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤ –** និយមន័យ

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

- មេជីវិតឈ្មោល សំដៅដល់កោសិកាបន្តពូជបុរស ។
- ម្ចាស់មេជីវិតឈ្មោល រួមមាន៖ អ្នកដាក់ពាក្យសុំ (ប្តី) អ្នកបរិច្ចាគមេជីវិតឈ្មោល ។
- មេជីវិតញី សំដៅដល់កោសិកាបន្តពូជស្ត្រី ។
- ម្ចាស់មេជីវិតញី រួមមាន៖ អ្នកដាក់ពាក្យសុំ (ប្រពន្ធ) អ្នកបរិច្ចាគមេជីវិតញី ។
- ការពពោះជំនួស សំដៅដល់ការពពោះដោយប្រើប្រាស់ ប្រភេទមួយនៃបច្ចេកវិទ្យាជំនួយការបង្កកំណើត (Assisted Reproductive Technologies) ដោយយកមេជីវិតញី និងមេជីវិតឈ្មោលពីសរីរាង្គមនុស្ស ដើម្បីបង្កើតអំប្រីយ៉ុងសម្រាប់ដាក់បញ្ចូលទៅក្នុងពោះស្ត្រីម្នាក់ផ្សេងទៀត ។
- បច្ចេកវិទ្យាជំនួយការបង្កកំណើត សំដៅដល់វិធីសាស្ត្រដែលអនុញ្ញាតឲ្យដកយកចេញនូវមេជីវិតញី ឬ ឈ្មោលពីសរីរាង្គមនុស្ស ដើម្បីធ្វើឲ្យមានផ្ទៃពោះក្នុងលក្ខណៈមិនមែនជាធម្មជាតិ។

- អំប្រីយ៉ុង សំដៅដល់សំណុំកោសិកាតំណជីវិត ក្នុងដំណាក់កាលទើបកកើតបានពីការជួបគ្នារវាងមេជីវិតឈ្មោល និងមេជីវិតញី និងកកើតជាជីវិតមួយថ្មី ដោយគិតចាប់ពីពេលចាប់ផ្ដើមរលាយចូលគ្នារវាងមេជីវិតឈ្មោល និងមេជីវិតញីរហូតរយៈពេល ០៨ (ប្រាំបី) សប្ដាហ៍ ។
- អំប្រីយ៉ុងបម្រុង សំដៅដល់អំប្រីយ៉ុងដែលរក្សាទុកសម្រាប់ជំនួសអំប្រីយ៉ុងដែលតោងមិនជាប់ (Embryo Implantation Unsuccessful) ។
- អ្នកពពោះជំនួស សំដៅដល់ស្ត្រីដែលទទួលដាក់អំប្រីយ៉ុងក្នុងពោះ តាមកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ។
- ទារកនៅក្នុងគភ៌ សំដៅដល់ទារកដែលមានអាយុលើសពី ០៨ (ប្រាំបី) សប្ដាហ៍ ដែលនៅក្នុងស្បូន ឬ នៅក្រៅស្បូន (ក្រៅអូវែមនុស្ស) ។
- ការធ្វើអាជីវកម្ម សំដៅដល់ការធ្វើសកម្មភាព ដើម្បីទទួលបានកម្រៃ សេវា ឬ ផលប្រយោជន៍ផ្សេងៗទៀត ដូចជា៖ ការលក់ ការដោះដូរ ការចែកចាយ ការចុះផ្សាយព័ត៌មាន ជាអាទិ៍ ។
- អ្នកវិជ្ជាជីវៈសុខាភិបាល សំដៅដល់គ្រូពេទ្យ ទន្តពេទ្យ ឆ្មប គិលានុបដ្ឋាក ឱសថការី អ្នកបច្ចេកទេសមន្ទីរពិសោធន៍សុខាភិបាល អ្នកព្យាបាលដោយចលនា ទន្តគិលានុបដ្ឋាក អ្នកបច្ចេកទេសវិទ្យុសាស្ត្រ និងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតដែលទទួលបានការចុះបញ្ជីការជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។
- អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល សំដៅដល់អ្នកវិជ្ជាជីវៈសុខាភិបាល ដែលទទួលបានអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈ ។

**មាត្រា ៥ –** គោលការណ៍ជាមូលដ្ឋាន

ច្បាប់នេះ កំណត់អំពីគោលការណ៍មូលដ្ឋានដូចខាងក្រោម៖

១- គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល ដែលពាក់ព័ន្ធនឹងការពពោះជំនួស ក្នុងការផ្ដល់លទ្ធភាព ចំពោះប្ដីប្រពន្ធដែលពុំអាចពពោះដោយខ្លួនឯងបាន ។

២- ហាមឃាត់ការធ្វើអាជីវកម្ម ដែលទាក់ទងនឹងការពពោះជំនួស ។

៣- គោរពសិទ្ធិ សេរីភាព សេចក្ដីថ្លៃថ្នូរ និងលើកកំពស់សុខុមាលភាព សុវត្ថិភាពរបស់ស្ត្រី ជាពិសេស ស្ត្រីដែលពពោះជំនួស ។

៤- គាំពារសុខុមាលភាព និងឧត្តមប្រយោជន៍កុមារដែលកើតដោយការពពោះជំនួស៖

- ឲ្យទទួលបាន ការបីបាច់ថែរក្សាពីគ្រួសារមួយ ដែលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ ។

- លើកកំពស់ផ្លូវចិត្ត (ផ្លូវអារម្មណ៍) ផ្លូវកាយរបស់កុមារដែលកើតពីការពពោះជំនួស ។
- ធានាក្នុងការការពារឲ្យកុមារដែលកើតពីការពពោះជំនួស ឲ្យទទួលបាននូវសិទ្ធិដូចគ្នាដូចកុមារទូទៅ ។

## ជំពូកទី ២

## រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច របស់ គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស គណៈកម្មការជំនាញ និង ការិយាល័យទទួលពាក្យសុំ

**មាត្រា ៦ --** គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស សរសេរអក្សរកាត់ គ.គ.ព.ជ ដែលដឹកនាំដោយរដ្ឋមន្ត្រីទទួលបន្ទុកវិស័យកិច្ចការនារី និងមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ ។

សមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧ --** តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស មានតួនាទី និងភារកិច្ច៖

១- ពិនិត្យពាក្យសុំ និងសំណុំឯកសារពពោះជំនួស ដែលការិយាល័យទទួលពាក្យសុំ បានបញ្ជូនមកគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

២- ពិនិត្យ និងសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យពពោះជំនួស ក្រោយពីបានទទួលលទ្ធផល និងយោបល់ពីគណៈកម្មការជំនាញ ។

៣- បង្គាប់ឲ្យគណៈកម្មការជំនាញ បញ្ចប់ជីវិតអំប្រីយ៉ុងបម្រុង ។

៤- ពិនិត្យ និងសម្រេចអំពីការទាមទារដែលមានចែងនៅក្នុងមាត្រា ៤៧ (សិទ្ធិដឹងអំពីកំណើតខ្លួនរបស់កូនសុំដែលកើតមកពីការពពោះជំនួស) នៃច្បាប់នេះ ។

៥- គ្រប់គ្រង ត្រួតពិនិត្យ និងតាមដានអំពីសេវាកម្មនៃបច្ចេកវិទ្យាជំនួយការបង្កកំណើត ដែលមានបញ្ញត្តិដោយច្បាប់ ឬ បទដ្ឋានគតិយុត្តនានា ។

៦- ពិនិត្យ តាមដាន អំពីការអនុវត្តច្បាប់ និងរៀបចំបំពេញបន្ថែម ចំពោះការខ្វះចន្លោះនៃបទប្បញ្ញត្តិគតិយុត្ត ។

៧- កិច្ចការផ្សេងទៀតដែលបានកំណត់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា ៨ --** គណៈកម្មការជំនាញ

ក្រសួងសុខាភិបាលត្រូវបង្កើតគណៈកម្មការជំនាញ ដើម្បីជួយដល់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស នៅក្នុងដំណើរការពពោះជំនួស ។

សមាសភាពគណៈកម្មការជំនាញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៩ --** តួនាទី និងភារកិច្ចរបស់គណៈកម្មការជំនាញ

គណៈកម្មការជំនាញ មានតួនាទី និងភារកិច្ចៈ

១- ធ្វើការផ្ទៀងផ្ទាត់ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំ ។

២- ពិនិត្យលើឯកសារបញ្ជាក់ពីគ្រូពេទ្យជំនាញអំពីការប្រឹក្សាយោបល់ផ្សេងៗ ដែលបានភ្ជាប់ជាមួយនឹងពាក្យសុំ ។

៣- ធ្វើការពិនិត្យសុខភាពរបស់ម្ចាស់មេជីវិតញី ឈ្មោល ឬ អ្នកពពោះជំនួស ក្នុងករណីយល់ឃើញថាចាំបាច់ ។

៤- ពិនិត្យមេជីវិតញី មេជីវិតឈ្មោល ក្នុងករណីយល់ឃើញថាចាំបាច់ ។

៥- ផ្តល់លទ្ធផល និងយោបល់ទាក់ទងនឹងការពិនិត្យ ដែលមានចែងនៅក្នុងចំណុចទី ១ រហូតដល់ចំណុចទី ៤ ខាងលើនេះ ទៅគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

៦- ត្រួតពិនិត្យ តាមដាន អំពីការប្រើប្រាស់អំប្រ៊ីយ៉ុង ការបញ្ចប់ជីវិតអំប្រ៊ីយ៉ុងបម្រុង តាមការចង្អុលបង្ហាញរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

៧- ផ្តល់យោបល់អំពីវិធីសាស្ត្រ និងចំណុចផ្សេងទៀត ទាក់ទងនឹងការប្រើប្រាស់អំប្រ៊ីយ៉ុង និងការរក្សាទុកអំប្រ៊ីយ៉ុងបម្រុង ទៅគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

៨- រក្សាទុកឯកសារព័ត៌មាន និងឯកសារផ្សេងៗដែលទាក់ទងនឹងចំណុចខាងលើ ។

៩- កិច្ចការផ្សេងទៀតដែលបានកំណត់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា ១០ --** ការិយាល័យទទួលពាក្យសុំ

១- ក្រសួងសុខាភិបាល ត្រូវរៀបចំឲ្យមានការិយាល័យទទួលពាក្យសុំពពោះជំនួស ដើម្បីជួយដល់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស នៅក្នុងដំណើរការពពោះជំនួស ។

២- ដើម្បីឲ្យអ្នកដាក់ពាក្យសុំ ធ្វើការជ្រើសរើស ការិយាល័យទទួលពាក្យសុំ ត្រូវមានបញ្ជីឈ្មោះ៖

ក- អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ដែលផ្តល់សេវាពពោះជំនួស និង

ខ- បញ្ជីឈ្មោះកន្លែងផ្តល់សេវាពពោះជំនួស ។

៣- បញ្ជីឈ្មោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងកន្លែងផ្តល់សេវាពពោះជំនួស ដែលមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ១១ --** តួនាទី និងភារកិច្ចរបស់ការិយាល័យទទួលពាក្យសុំ

ការិយាល័យទទួលពាក្យសុំមានតួនាទី និងភារកិច្ច៖

១- ពិនិត្យពាក្យសុំពពោះជំនួស និងឯកសារភ្ជាប់ ។

២- បង្គាប់ឲ្យធ្វើការកែតម្រូវពាក្យសុំពពោះជំនួស ។

៣- គ្រប់គ្រង រក្សាទុកពន្ធដាក់ពាក្យសុំពពោះជំនួស និងសោហ៊ុយចំណាយផ្សេងៗដែលទាក់ទងនឹងការពពោះជំនួស ។

៤- រក្សាទុកជានិរន្ត នូវរាល់ឯកសារពាក់ព័ន្ធនឹងពាក្យសុំពពោះជំនួស និងឯកសារព័ត៌មានដែលសម្រេចដោយគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស និងឯកសារពាក់ព័ន្ធដទៃទៀត ។

៥- ទទួលការជូនដំណឹងអំពីការរំលាយកិច្ចសន្យារបស់ភាគីនៃការពពោះជំនួស ហើយបញ្ជូនការជូនដំណឹងនោះទៅគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

៦- ជូនដំណឹងអំពីឈ្មោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលផ្តល់សេវាពពោះជំនួស និងកន្លែងផ្តល់សេវាពពោះជំនួស ដែលអ្នកដាក់ពាក្យសុំបានជ្រើសរើសសម្រាប់ផ្តល់បច្ចេកវិទ្យាជំនួយការបង្កកំណើតទៅគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

៧- ផ្តល់ព័ត៌មានទាក់ទងនឹងការទាមទារដែលមានចែងនៅក្នុងមាត្រា ៤៧ (សិទ្ធិដឹងអំពីកំណើតខ្លួនរបស់កូនសុំដែលកើតមកពីការពពោះជំនួស) នៃច្បាប់នេះ តាមការសម្រេចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

៨- កិច្ចការផ្សេងទៀតដែលបានកំណត់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត ។

# ជំពូកទី៣

# លក្ខខណ្ឌ និងនីតិវិធីនៃការពពោះជំនួស

## ផ្នែកទី ១

## លក្ខខណ្ឌនៃការពពោះជំនួស

**មាត្រា ១២ --** ការបង្កើតអំប្រីយ៉ុង

អំប្រីយ៉ុងត្រូវបានបង្កើតឡើង តាមវិធីដូចខាងក្រោម៖

១- ដោយប្រើប្រាស់មេជីវិតឈ្មោលរបស់បុរស និងមេជីវិតញីរបស់ស្ត្រីដែលដាក់ពាក្យសុំពពោះជំនួស ។

២- ដោយប្រើប្រាស់មេជីវិតឈ្មោលរបស់បុរស ឬ មេជីវិតញីរបស់ស្ត្រីដែលដាក់ពាក្យសុំជាមួយនឹងមេជីវិតឈ្មោល ឬ មេជីវិតញីរបស់តតិយជន (អ្នកបរិច្ចាគមេជីវិត) តែមិនមែនជាមេជីវិតញីរបស់អ្នកពពោះជំនួសនោះឡើយ ។

**មាត្រា ១៣ --** លក្ខខណ្ឌរបស់ប្តីប្រពន្ធដែលដាក់ពាក្យសុំ

១- ប្តីប្រពន្ធដែលដាក់ពាក្យសុំត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក- ត្រូវមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ។

ខ- ត្រូវមានសញ្ជាតិខ្មែរទាំងពីរនាក់ ។

គ- ប្តីប្រពន្ធត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ដល់អាយុ ៤៥ (សែសិបប្រាំ) ឆ្នាំ ។

ឃ- ប្តីប្រពន្ធដែលមិនអាចមានកូនបង្កើតដោយខ្លួនឯង (ប្តី ឬ ប្រពន្ធគ្មានលទ្ធភាព ឬ សមត្ថភាពខ្សោយ)។

ង- អ្នកដាក់ពាក្យសុំ មិនមានកូនដែលកើតពីការពពោះជំនួស នៅពេលដាក់ពាក្យសុំ ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ចំណុច «ខ» ខាងលើនេះក៏ដោយ ក្នុងករណីដែលសហព័ទ្ធម្ខាងមិនមែនជាជនជាតិខ្មែរ ប្តីប្រពន្ធអាចដាក់ពាក្យសុំបាន លុះត្រាតែសហព័ទ្ធម្ខាងដែលមិនមែនជាជនជាតិខ្មែរនោះបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់យ៉ាងតិច ០៣ (បី) ឆ្នាំមុនពេលដាក់ពាក្យសុំ ។

៣- ក្រៅពីបញ្ញត្តិនៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើនេះ បញ្ញត្តិនៃច្បាប់ស្តីពី សុំកូនអន្តរប្រទេស ត្រូវអនុវត្តចំពោះករណីដែលប្តីប្រពន្ធសងខាង ឬ ណាម្ខាងនៃអ្នកដាក់ពាក្យសុំនោះរស់នៅបរទេស ។

**មាត្រា ១៤ --** លក្ខខណ្ឌរបស់អ្នកបរិច្ចាគមេជីវិត

អ្នកបរិច្ចាគមេជីវិត ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

១- ត្រូវមានសញ្ជាតិខ្មែរ ។

២- ត្រូវមានអាយុយ៉ាងតិច ១៨ (ដប់ប្រាំបី) ឆ្នាំ និងយ៉ាងច្រើន ៤៥ (សែសិបប្រាំ) ឆ្នាំ ។

៣- មិនមែនជាបុព្វញាតិ ឬ បច្ឆាញាតិផ្ទាល់ របស់អ្នកដាក់ពាក្យសុំ ។

៤- មិនមែនជាសាខាញាតិលោហិតក្នុង ០៣ (បី) ថ្នាក់ របស់អ្នកដាក់ពាក្យសុំណាម្ខាង ក្នុងករណីដែលមេជីវិតរបស់អ្នកដាក់ពាក្យសុំម្ខាងនោះ ត្រូវបានយកមកប្រើ ដើម្បីបង្កើតអំប្រ៊ីយ៉ុង ។

៥- មិនមែនជាអ្នកពពោះជំនួស ឬ សហព័ទ្ធរបស់អ្នកពពោះជំនួស ។

៦- ត្រូវមានការយល់ព្រមដោយស្ម័គ្រចិត្តរបស់អ្នកបរិច្ចាគមេជីវិត ។ ក្នុងករណីអ្នកបរិច្ចាគមេជីវិតមានសហព័ទ្ធ ត្រូវមានការយល់ព្រមពីសហព័ទ្ធរបស់អ្នកបរិច្ចាគមេជីវិតនោះផងដែរ ។

៧- ពុំមានជំងឺតំណពូជ មានសុខភាពល្អ ឬ ពុំមានជំងឺឆ្លងតាមកោសិកាមេជីវិតញី ឬ ឈ្មោល ។

៨- ពុំធ្លាប់បរិច្ចាគ សម្រាប់ករណីពពោះជំនួសពីមុនមក ។ ចំពោះមេជីវិតញី ទោះបីជាការបរិច្ចាគនោះ ធ្វើក្នុងករណីការពពោះជំនួសតែមួយក៏ដោយ ក៏អនុញ្ញាតឲ្យបរិច្ចាគយ៉ាងច្រើនត្រឹម ០៣ (បី) ដងប៉ុណ្ណោះ ។

**មាត្រា ១៥ --** លក្ខខណ្ឌរបស់អ្នកពពោះជំនួស

អ្នកពពោះជំនួស ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

១- ត្រូវមានសញ្ជាតិខ្មែរ ។

២- ត្រូវមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ដល់ ៤០ (សែសិប) ឆ្នាំ ។

៣- ត្រូវមានការយល់ព្រមដោយស្ម័គ្រចិត្តពីអ្នកពពោះជំនួស ។

៤- ត្រូវតែជាស្ត្រីដែលមានសហព័ទ្ធ និងមានការយល់ព្រមពីសហព័ទ្ធរបស់ស្ត្រីនោះ និងជាស្ត្រីដែលធ្លាប់មានកូនមុនការពពោះជំនួស ។

៥- មិនមែនជាបុព្វញាតិ ឬ ជាបច្ឆាញាតិផ្ទាល់ នៃអ្នកដាក់ពាក្យសុំ ។

៦- ត្រូវតែជាសាខាញាតិលោហិត របស់អ្នកដាក់ពាក្យសុំណាម្ខាង ។

៧- ជាស្ត្រីដែលមិនធ្លាប់ពពោះជំនួសពីមុនមក និងគ្មានផ្ទៃពោះ នៅពេលដាក់ពាក្យសុំពពោះជំនួស។

## ផ្នែកទី២
## កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

**មាត្រា ១៦ -** និយមន័យនៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស សំដៅទៅលើកិច្ចសន្យាដែលប្តីប្រពន្ធដាក់ពាក្យសុំពពោះជំនួស ឲ្យអ្នកទទួលពពោះជំនួស ពពោះ និងបង្កើតកូនជំនួសខ្លួន ហើយសុំកូនដែលកើតមកតាមរយៈការពពោះជំនួសនោះ ។

**មាត្រា ១៧ -** ទម្រង់នៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

១- ឈ្មោះ និងអាសយដ្ឋាន របស់ប្តីប្រពន្ធដែលនឹងត្រូវដាក់ពាក្យសុំ និងលេខអត្តសញ្ញាណ-ប័ណ្ណ លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់ប្តីប្រពន្ធដែលនឹងត្រូវដាក់ពាក្យសុំ ។

២- ឈ្មោះ និងអាសយដ្ឋាន របស់អ្នកដែលត្រូវពពោះជំនួស និងលេខអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកដែលត្រូវពពោះជំនួស ។

៣- ឈ្មោះ និងអាសយដ្ឋាន របស់អ្នកដែលនឹងត្រូវបរិច្ចាគមេជីវិត និងលេខអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកដែលនឹងត្រូវបរិច្ចាគមេជីវិត ក្នុងករណីដែលមានអ្នកបរិច្ចាគមេជីវិត ។

៤- ខ្លឹមសារនៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ដូចមានចែងនៅក្នុងមាត្រា ១៨ (ខ្លឹមសារនៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស) នៃច្បាប់នេះ ។

៥- កាលបរិច្ឆេទនៃការបង្កើតកិច្ចសន្យា ។

៦- ហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ប្តីប្រពន្ធដាក់ពាក្យសុំ អ្នកពពោះជំនួស និងសហព័ទ្ធ (ក្នុងករណីដែលមានអ្នកបរិច្ចាគមេជីវិត ក៏ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកបរិច្ចាគមេជីវិត និងសហព័ទ្ធ ប្រសិនបើអ្នកបរិច្ចាគមេជីវិតនោះមានសហព័ទ្ធ) ។

**មាត្រា ១៨ --** ខ្លឹមសារនៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ចាំបាច់ត្រូវតែមានខ្លឹមសារសំខាន់ដូចខាងក្រោម៖

១- ការព្រមព្រៀងរវាងអ្នកដាក់ពាក្យសុំ និងអ្នកពពោះជំនួស ក្នុងការប្រើប្រាស់បច្ចេកវិទ្យាជំនួយការបង្កកំណើត ដើម្បីដាក់អំប្រ៊ីយ៉ុងបញ្ចូលទៅក្នុងពោះអ្នកពពោះជំនួស ។

២- ការព្រមព្រៀងរវាងអ្នកដាក់ពាក្យសុំ និងអ្នកពពោះជំនួស ក្នុងការចំណាយដែលទាក់ទងនឹងនីតិវិធីនៃការពពោះជំនួស ។

៣- ការព្រមព្រៀងរវាងអ្នកដាក់ពាក្យសុំ និងអ្នកពពោះជំនួស ព្រមទាំងសហព័ទ្ធរបស់អ្នកពពោះជំនួស ទាក់ទងនឹងការដាក់ពាក្យសុំកូនដែលកើតពីការពពោះជំនួសនោះ ។

៤- ការព្រមព្រៀងរវាងអ្នកដាក់ពាក្យសុំ អ្នកពពោះជំនួសនិងសហព័ទ្ធ និងអ្នកបរិច្ចាគមេជីវិត (ក្នុងករណីដែលមានអ្នកបរិច្ចាគមេជីវិត) និងសហព័ទ្ធ (ក្នុងករណីអ្នកបរិច្ចាគមេជីវិតមានសហព័ទ្ធ) ក្នុងការរក្សាការសម្ងាត់អំពីការពពោះជំនួស ។

**មាត្រា ១៩ --** ការរំលាយកិច្ចសន្យា ទាក់ទងនឹងការពពោះជំនួស

១- ភាគីនៃកិច្ចសន្យាអាចស្នើសុំរំលាយកិច្ចសន្យាបាន ក្នុងករណីណាមួយដូចខាងក្រោម៖

ក- គុណភាពនៃមេជីវិតរបស់អ្នកដាក់ពាក្យសុំ ឬ អ្នកបរិច្ចាគមេជីវិតមិនអាចធ្វើការបង្កកំណើតបាន ។

ខ- អំប្រ៊ីយ៉ុងមិនទាន់បានដាក់បញ្ចូលក្នុងសរីរាង្គបន្តពូជស្ត្រីដែលទទួលពពោះជំនួស ។

គ- មានការបញ្ជាក់ពីពេទ្យថា សុខភាពរបស់អ្នកពពោះជំនួសនោះ មិនអាចបន្តពពោះតទៅទៀតបាន ។

ឃ- អ្នកពពោះជំនួសបានចេញពីលំនៅដ្ឋាន ឬ ទីសំណាក់របស់ខ្លួន ហើយពុំអាចរកឃើញ (មុនពេលដាក់បញ្ចូលអំប្រ៊ីយ៉ុង ឬ ក្រោយពេលដាក់បញ្ចូលអំប្រ៊ីយ៉ុង) ។

ង- មូលហេតុផ្សេងទៀត ដែលការបន្តកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស មានភាពពិបាកយ៉ាងខ្លាំង ។ ប៉ុន្តែនៅក្រោយពេលដែលអំប្រីយ៉ុងត្រូវបានដាក់បញ្ចូលក្នុងសរីរាង្គបន្តពូជស្ត្រី ដែលទទួលពពោះជំនួសហើយ ភាគីដែលដាក់ពាក្យសុំទាំងសងខាង ឬ ណាម្ខាង មិនអាចយកមូលហេតុត្រឹមតែការលែងលះ ឬ ការទទួលមរណភាពរបស់ភាគីណាម្ខាងមករំលាយកិច្ចសន្យាបានឡើយ ។

២- ក្នុងករណីកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ត្រូវបានរំលាយដោយមានមូលហេតុដូចបានរៀបរាប់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដាក់ពាក្យសុំ ត្រូវជូនដំណឹងទៅការិយាល័យទទួលពាក្យសុំ ។ បញ្ញត្តិនេះមិនរារាំងដល់អ្នកពពោះជំនួស ធ្វើការជូនដំណឹងទៅការិយាល័យទទួលពាក្យសុំឡើយ ។

**មាត្រា ២០ --** បញ្ញត្តិពិសេសអំពីការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

១- ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ដោយយកមូលហេតុដែលមានចែងក្នុងចំណុច «ឃ» កថាខណ្ឌទី ១ នៃមាត្រា ១៩ (ការរំលាយកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស) នៃច្បាប់នេះ ត្រូវធ្វើឡើងតាមវិធីនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលមានចែងនៅក្នុងមាត្រា ២៥៦ (របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយការបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់សាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅដ្ឋាន ឬ ទីសំណាក់របស់អ្នកពពោះជំនួស ។

២- ការបង្ហាញឆន្ទៈដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា បានដល់អ្នកពពោះជំនួស នៅពេលដែលអំឡុងពេល ០២ (ពីរ) សប្តាហ៍បានកន្លងផុត គិតចាប់ពីថ្ងៃដែលតុលាការបានបិទប្រកាស លើកលែងតែករណីអ្នកពពោះជំនួសនោះបានបង្ហាញខ្លួនមុនអំឡុងពេល ០២ (ពីរ) សប្តាហ៍នោះបានកន្លងផុត ។

៣- ចំពោះសោហ៊ុយនៃការបិទប្រកាស ដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ។

**មាត្រា ២១ --** ការបញ្ចប់កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស

១- កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ត្រូវបានបញ្ចប់នៅពេលដែលអ្នកពពោះជំនួសបានទទួលមរណភាពមុនពេលដែលទារកនៅក្នុងគភ៌មានកំណើត លើកលែងតែករណីទារកនៅក្នុងគភ៌នោះបានជួយសង្គ្រោះ ហើយមានជីវិត នៅពេលដែលអ្នកពពោះជំនួសនោះបានទទួលមរណភាព ។

២- ក្នុងករណីអ្នកពពោះជំនួសបានទទួលមរណភាពក្រោយពេលដែលទារកនៅក្នុងគភ៌ មានកំណើតហើយមានជីវិត នោះកិច្ចសន្យាមិនត្រូវបញ្ចប់បានឡើយ ។

# ផ្នែកទី ៣
# នីតិវិធីនៃការដាក់ពាក្យសុំពពោះជំនួស

**មាត្រា ២២ –** របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

១- ពាក្យសុំពពោះជំនួស ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងដាក់ទៅការិយាល័យទទួលពាក្យសុំនៃក្រសួងសុខាភិបាល ។

២- នៅក្នុងពាក្យសុំពពោះជំនួស ត្រូវសរសេរបញ្ជាក់នូវចំណុចទាំងអស់ដូចខាងក្រោមនេះ៖

ក- ឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងមុខរបររបស់ប្តីប្រពន្ធដែលដាក់ពាក្យសុំ ។

ខ- ឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងមុខរបររបស់អ្នកពពោះជំនួស និងសហព័ទ្ធ ។

គ- ឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងមុខរបររបស់អ្នកបរិច្ចាគមេជីវិត ប្រសិនបើមាន និងឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋានរបស់សហព័ទ្ធ ក្នុងករណីអ្នកបរិច្ចាគមេជីវិតមានសហព័ទ្ធ ។

ឃ- កម្មវត្ថុនៃការដាក់ពាក្យសុំ (ការស្នើសុំអនុញ្ញាតឲ្យមានការពពោះជំនួស) ។

ង- មូលហេតុនៃការដាក់ពាក្យសុំ ។

ច- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមម្រាមដៃ របស់ប្តីប្រពន្ធដែលដាក់ពាក្យសុំ ។

៣- ក្រៅពីចំណុចដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស អាចចេញប្រកាសកំណត់អំពីចំណុចផ្សេងទៀត ដែលត្រូវសរសេរនៅក្នុងពាក្យសុំ ប្រសិនបើយល់ឃើញថាចាំបាច់ ។

**មាត្រា ២៣ –** ឯកសារភ្ជាប់ជាមួយពាក្យសុំពពោះជំនួស

១- នៅពេលដាក់ពាក្យសុំពពោះជំនួស អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនូវឯកសារចាំបាច់មួយចំនួនដូចខាងក្រោម៖

ក- កិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ។

ខ- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ របស់ប្តីប្រពន្ធអ្នកដាក់ពាក្យសុំ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ។

គ- អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀត ដែលអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់ប្តីប្រពន្ធអ្នកដាក់ពាក្យសុំ អ្នកពពោះជំនួសនិងសហព័ទ្ធ និងអ្នកបរិច្ចាគមេជីវិត ប្រសិនបើមាន និងសហព័ទ្ធ ក្នុងករណីអ្នកបរិច្ចាគមេជីវិតមានសហព័ទ្ធ ។

ឃ- លិខិតថ្កោលទោស ដែលមានសុពលភាព នៅពេលដាក់ពាក្យសុំ របស់ប្តីប្រពន្ធអ្នកដាក់ពាក្យសុំ ។ ក្នុងករណីដែលភាគីណាម្ខាងនៃអ្នកដាក់ពាក្យសុំ មិនមែនជាជនជាតិខ្មែរ ត្រូវមានលិខិតបញ្ជាក់ថា ពុំដែលមានទោសពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ជននោះ ។

ង- លិខិតបញ្ជាក់ពីការប្រឹក្សាយោបល់ពីគ្រូពេទ្យជំនាញអំពីអលទ្ធភាព ឬ សមត្ថភាពខ្សោយក្នុងការពពោះរបស់ប្តីប្រពន្ធដែលដាក់ពាក្យសុំ ។

ច- លិខិតបញ្ជាក់ពីការប្រឹក្សាយោបល់ពីគ្រូពេទ្យជំនាញផ្នែកទូទៅ ផ្នែកចិត្តសាស្ត្រ ផ្នែកសម្ភព ផ្នែកហ្សែន ផ្នែកបច្ចេកវិទ្យាក្នុងការពពោះជំនួស ជាអាទិ៍ ប្រសិនបើមាន ។

ឆ- ឯកសារដែលបង្ហាញពីស្ថានភាពសេដ្ឋកិច្ចរបស់អ្នកដាក់ពាក្យសុំ ។

ជ- របាយការណ៍ទាក់ទងទៅនឹងប្រវត្តិគ្រួសាររបស់អ្នកបរិច្ចាគមេជីវិត ដែលបញ្ជាក់ថាមានសុខភាពល្អ ពុំមានជំងឺតំណពូជ ឬ ពុំមានជំងឺឆ្លងតាមកោសិកាមេជីវិតញី ឬ ឈ្មោល ក្នុងករណីមានអ្នកបរិច្ចាគមេជីវិត ។

**មាត្រា ២៤ –** ការប្រគល់ច្បាប់ដើមនៃអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀត

១- ការិយាល័យទទួលពាក្យសុំ ត្រូវប្រគល់អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀត ដែលអាចបញ្ជាក់អំពីអត្តសញ្ញាណ ដែលមានចែងនៅក្នុងចំណុច «គ» នៃមាត្រា ២៣ (ឯកសារភ្ជាប់ជាមួយពាក្យសុំពពោះជំនួស) នៃច្បាប់នេះ ឲ្យទៅអ្នកដាក់ពាក្យសុំវិញ ។

២- ដើម្បីទទួលអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំនូវសេចក្តីចម្លងអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀតនោះ ដែលមានបញ្ជាក់ថា បានចម្លងត្រឹមត្រូវពីច្បាប់ដើម ពីអាជ្ញាធរមានសមត្ថកិច្ច ។

៣- នៅពេលដែលការិយាល័យទទួលពាក្យសុំ ប្រគល់ច្បាប់ដើម នៃអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬ ឯកសារផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ការិយាល័យទទួលពាក្យសុំ ត្រូវឲ្យអ្នកទទួលការប្រគល់ សរសេរនៅក្នុងសេចក្តីចម្លងនៃអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬ

ឯកសារផ្សេងទៀតនោះ ថាខ្លួនបានទទួលច្បាប់ដើមនោះវិញហើយ ព្រមទាំងចុះហត្ថលេខា ឬ ស្នាមម្រាមដៃ ។

**មាត្រា ២៥ –** ការពិនិត្យពាក្យសុំពពោះជំនួសដោយការិយាល័យទទួលពាក្យសុំ

១- ក្នុងករណីពាក្យសុំពពោះជំនួស និងឯកសារភ្ជាប់មិនមានលក្ខណៈត្រឹមត្រូវ និងគ្រប់គ្រាន់ដូចមានចែងនៅក្នុងមាត្រា ២២ (របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ) និងមាត្រា ២៣ (ឯកសារភ្ជាប់ជាមួយពាក្យសុំពពោះជំនួស) នៃច្បាប់នេះ ការិយាល័យទទួលពាក្យសុំ ត្រូវចេញលិខិតបង្គាប់ឲ្យកែតម្រូវនូវចំណុចខ្វះខាតនោះ ដោយកំណត់អំឡុងពេលសមរម្យ ។

២- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានធ្វើការកែតម្រូវទេ ការិយាល័យទទួលពាក្យសុំត្រូវធ្វើលិខិតលើកចោលពាក្យសុំពពោះជំនួសនោះ និងជូនដំណឹងអំពីការលើកចោលនោះ ទៅអ្នកដាក់ពាក្យសុំ ដើម្បីឲ្យអ្នកដាក់ពាក្យសុំមកទទួលលិខិតនោះ ។

៣- ចំពោះការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ការិយាល័ទទួលពាក្យសុំ ត្រូវធ្វើតាមមធ្យោបាយសមរម្យ ។

**មាត្រា ២៦ –** លិខិតបង្គាប់ឲ្យកែតម្រូវ និងលិខិតលើកចោល

ចំពោះលិខិតបង្គាប់ឲ្យកែតម្រូវ និងលិខិតលើកចោលដូចមានចែងនៅក្នុងមាត្រា ២៥ (ការពិនិត្យពាក្យសុំពពោះជំនួសដោយការិយាល័យទទួលពាក្យសុំ) ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានការចុះហត្ថលេខា និងឈ្មោះរបស់ប្រធានការិយាល័យទទួលពាក្យសុំ ។

**មាត្រា ២៧ –** ការបញ្ជូនពាក្យសុំពពោះជំនួស

បើពាក្យសុំពពោះជំនួសមានភាពត្រឹមត្រូវស្របតាមមាត្រា ២២ (របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ) និងមាត្រា ២៣ (ឯកសារភ្ជាប់ជាមួយពាក្យសុំពពោះជំនួស) នៃច្បាប់នេះ ការិយាល័យទទួលពាក្យសុំ ត្រូវធ្វើដីកាបញ្ជូនពាក្យសុំ និងឯកសារភ្ជាប់ទៅគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

**មាត្រា ២៨ –** ការពិនិត្យពាក្យសុំពពោះជំនួស និងឯកសារភ្ជាប់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

១- ក្នុងករណីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស យល់ឃើញថា ពាក្យសុំពពោះជំនួស និងឯកសារភ្ជាប់ មានលក្ខណៈត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់នេះហើយ គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ត្រូវធ្វើលិខិតបង្គាប់ឲ្យគណៈកម្មការជំនាញ ធ្វើការពិនិត្យ និងផ្តល់យោបល់ទាក់ទងទៅនឹងបច្ចេកវិទ្យាជំនួយការបង្កកំណើត ។

២- ក្នុងករណីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស យល់ឃើញថា ពាក្យសុំពពោះជំនួស និងឯកសារភ្ជាប់ មានចំណុចត្រូវបំពេញ ឬ បន្ថែម គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ត្រូវធ្វើលិខិតបង្គាប់ដោយបញ្ជាក់នូវចំណុចដែលត្រូវបំពេញ ឬ បន្ថែម ដោយកំណត់អំឡុងពេលសមរម្យទៅឲ្យអ្នកដាក់ពាក្យសុំ តាមរយៈការិយាល័យទទួលពាក្យសុំ ។

៣- ក្រោយពីទទួលបានលិខិតបង្គាប់ដែលមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ពីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួសហើយ ការិយាល័យទទួលពាក្យសុំ ត្រូវធ្វើលិខិតជូនដំណឹងផ្ញើទៅអ្នកដាក់ពាក្យសុំ ដោយភ្ជាប់ជាមួយនឹងលិខិតបង្គាប់របស់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួសនោះ ។

៤- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានធ្វើការបំពេញ ឬ បន្ថែមទេ គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ត្រូវធ្វើលិខិតលើកចោលពាក្យសុំពពោះជំនួស និងជូនដំណឹងអំពីការលើកចោលនោះទៅអ្នកដាក់ពាក្យសុំ តាមរយៈការិយាល័យទទួលពាក្យសុំ ដើម្បីឲ្យអ្នកដាក់ពាក្យសុំមកទទួលលិខិតនោះ ។

៥- ចំពោះការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ ការិយាល័យទទួលពាក្យសុំត្រូវធ្វើតាមមធ្យោបាយសមរម្យ។

៦- ចំពោះការលើកចោល ដែលមានចែងនៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អ្នកដាក់ពាក្យសុំមិនអាចដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣១ (ពាក្យសុំឲ្យពិនិត្យឡើងវិញ ចំពោះការលើកចោលពាក្យសុំពពោះជំនួសរបស់ការិយាល័យទទួលពាក្យសុំ) បានឡើយ ។

**មាត្រា ២៩ --** ការពិនិត្យការបញ្ជូនលទ្ធផល និងយោបល់ដោយគណៈកម្មការជំនាញ

នៅពេលដែលគណៈកម្មការជំនាញ ទទួលការបង្គាប់ពីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស គណៈកម្មការជំនាញ ត្រូវពិនិត្យលើបច្ចេកវិទ្យាជំនួយការបង្កកំណើត និងបញ្ជូនលទ្ធផល និងយោបល់ទៅគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

**មាត្រា ៣០.-** ការពិនិត្យ និងសម្រេចដោយគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

១- ក្រោយពីទទួលបានលទ្ធផល និងយោបល់ពីគណៈកម្មការជំនាញហើយ គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ត្រូវពិនិត្យ និងសម្រេចអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យពពោះជំនួស ដោយធ្វើលិខិតជាលាយលក្ខណ៍អក្សរ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំ តាមរយៈការិយាល័យទទួលពាក្យសុំ ដើម្បីឲ្យអ្នកដាក់ពាក្យសុំមកទទួលលិខិតនោះ ។

២- ចំពោះការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ការិយាល័យទទួលពាក្យសុំត្រូវធ្វើតាមមធ្យោបាយសមរម្យ ។

## ផ្នែកទី៤

## នីតិវិធីនៃការដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ និងការប្តឹងតវ៉ា

**មាត្រា ៣១ .-** ពាក្យសុំឲ្យពិនិត្យឡើងវិញ ចំពោះការលើកចោលពាក្យសុំពពោះជំនួសរបស់ការិយាល័យទទួលពាក្យសុំ

១- ចំពោះការលើកចោលពាក្យសុំពពោះជំនួសរបស់ការិយាល័យទទួលពាក្យសុំ ដូចមានចែងនៅក្នុងមាត្រា ២៥ (ការពិនិត្យពាក្យសុំពពោះជំនួសដោយការិយាល័យទទួលពាក្យសុំ) នៃច្បាប់នេះ អ្នកដាក់ពាក្យសុំពពោះជំនួស មានសិទ្ធិដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ។

២- ក្នុងករណីមានពាក្យសុំឲ្យពិនិត្យឡើងវិញ ដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស យល់ឃើញថា ការលើកចោលពាក្យសុំពពោះជំនួសរបស់ការិយាល័យទទួលពាក្យសុំ គ្មានមូលហេតុត្រឹមត្រូវទេ គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ត្រូវលុបចោលនូវការលើកចោលពាក្យសុំពពោះជំនួស របស់ការិយាល័យទទួលពាក្យសុំនោះ ហើយជូនដំណឹងអំពីការលុបចោលនោះ ទៅអ្នកដាក់ពាក្យសុំ តាមរយៈការិយាល័យទទួលពាក្យសុំ ដើម្បីឲ្យអ្នកដាក់ពាក្យសុំមកទទួលលិខិតនោះ រួចបន្តនីតិវិធីដែលមានចែងនៅក្នុងមាត្រា ២៨ (ការពិនិត្យពាក្យសុំពពោះជំនួស និងឯកសារភ្ជាប់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស) នៃច្បាប់នេះ ។

៣- ក្នុងករណីមានពាក្យសុំឲ្យពិនិត្យឡើងវិញ ដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស យល់ឃើញថា ការលើកចោលពាក្យសុំពពោះជំនួសរបស់ការិយាល័យទទួលពាក្យសុំ មានមូលហេតុត្រឹមត្រូវ គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះ

ជំនួស ត្រូវធ្វើលិខិតលើកចោលពាក្យសុំឲ្យពិនិត្យឡើងវិញនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំតាមរយៈការិយាល័យទទួលពាក្យសុំ ដើម្បីឲ្យអ្នកដាក់ពាក្យសុំមកទទួលលិខិតនោះ ។

៤- ចំពោះការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ ខាងលើនេះ ការិយាល័យទទួលពាក្យសុំត្រូវធ្វើតាមមធ្យោបាយសមរម្យ ។

៥- ចំពោះការលើកចោល ដែលមានចែងនៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អ្នកដាក់ពាក្យសុំមិនអាចដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញម្តងទៀតបានឡើយ ។

**មាត្រា ៣២ --** ការប្តឹងតវ៉ា ចំពោះសេចក្តីសម្រេចទាក់ទងទៅនឹងការពពោះជំនួសរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

អ្នកដាក់ពាក្យសុំអាចប្តឹងតវ៉ាទៅតុលាការ ចំពោះសេចក្តីសម្រេចទាក់ទងទៅនឹងការពពោះជំនួសរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួសបាន ដោយអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៤
## ការអនុវត្តការពពោះជំនួស និងការតាមដានក្រោយពីការដាក់អំប្រ៊ីយ៉ុង

**មាត្រា៣៣ --** ការជ្រើសរើសកន្លែងផ្តល់បច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើឲ្យការពពោះជំនួស

ក្រោយពីទទួលបានការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួសហើយ អ្នកដាក់ពាក្យសុំ និងអ្នកពពោះជំនួស អាចសម្រេចជ្រើសរើសអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងកន្លែងសម្រាប់ផ្តល់សេវាពពោះជំនួស ពីបញ្ជីដែលមានចែងនៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១០ (ការិយាល័យទទួលពាក្យសុំ) នៃច្បាប់នេះ ហើយផ្តល់ព័ត៌មានអំពីអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងកន្លែងដែលបានជ្រើសរើសនោះ ជូនទៅគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួសតាមរយៈការិយាល័យទទួលពាក្យសុំ ។

**មាត្រា ៣៤ --** ការផ្តល់សេវាកម្មលើបច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើឲ្យការពពោះជំនួស

១- អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ផ្នែកបច្ចេកវិទ្យាជំនួយការបង្កកំណើត ដែលផ្តល់សេវាកម្មបច្ចេកវិទ្យាជំនួយការបង្កកំណើតត្រូវពិនិត្យ និងវាយតម្លៃលើអ្នកពពោះជំនួស ម្ចាស់មេជីវិតញី ឈ្មោល

ទាំងសុខភាពរាងកាយ ផ្លូវចិត្ត ដើម្បីការពារជម្ងឺផ្សេងៗ ដែលអាចឆ្លងទៅកាន់ទារកដែលនៅក្នុងគភ៌ និងការពារឧត្តមប្រយោជន៍របស់កុមារ ។

២- អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្នែកបច្ចេកវិទ្យាជំនួយការបង្កកំណើត ត្រូវយកអំប្រីយ៉ុងតែមួយគត់ទៅដាក់នៅក្នុងស្បូនអ្នកពពោះជំនួស ហើយអំប្រីយ៉ុងនោះ ត្រូវបង្កើតឡើងដោយមិនទាក់ទងនឹងការជ្រើសរើសភេទ ។

៣- បែបបទ និងនីតិវិធីនៃការត្រួតពិនិត្យ វាយតម្លៃ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៣៥ ៈ** ការរក្សាទុក ការប្រើប្រាស់ និងការបញ្ចប់អត្ថិភាពនៃមេជីវិត និងអំប្រីយ៉ុង

ការរក្សាទុក ការប្រើប្រាស់ និងការបញ្ចប់អត្ថិភាពនៃមេជីវិត និងអំប្រីយ៉ុង ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលកំណត់ដោយក្រសួងសុខាភិបាល ។

**មាត្រា ៣៦ ៈ** ការតាមដាន ការប្រើប្រាស់បច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើឲ្យការពពោះជំនួស

គណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ត្រូវតាមដានការប្រើប្រាស់បច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើឲ្យការពពោះជំនួស នៅគ្រប់ដំណាក់កាលដូចខាងក្រោមនេះ៖

១- ដំណាក់កាល យកមេជីវិត ។

២- ដំណាក់កាលផ្សាំមេជីវិតញី ឈ្មោល ។

៣- អំឡុងពេលមានគភ៌ ។

៤- ពេលសម្រាលកូន ។

៥- ក្រោយពេលសម្រាលកូន ។

**មាត្រា ៣៧ ៈ** ការរំលូតកូន

យោងទៅតាមបញ្ញត្តិនៃច្បាប់ស្តីពីការរំលូតកូន អ្នកពពោះជំនួស អាចរំលូតកូនបាន ។ ប៉ុន្តែទោះបីជាមានបញ្ញត្តិនៅក្នុងមាត្រា ៨ នៃច្បាប់ស្តីពីការរំលូតកូនក៏ដោយ ប្រសិនបើគភ៌មានអាយុតិចជាង ១២ (ដប់ពីរ)សប្តាហ៍ អ្នកពពោះជំនួស អាចរំលូតកូនបាន លុះត្រាតែមានការយល់ព្រមពីអ្នកដាក់ពាក្យសុំ ។

# ជំពូកទី ៥
# ការសម្រេចអំពីបុត្តភាព

**មាត្រា ៣៨ --** មាតុភាព

អនុលោមតាមមាត្រា ៩៨៧ (មាតុភាព) នៃក្រមរដ្ឋប្បវេណី អ្នកពពោះជំនួស គឺជាម្តាយរបស់កូន ដែលកើតដោយការពពោះជំនួស ។

**មាត្រា ៣៩ --** ការសន្មតបិតុភាព

អនុលោមតាមមាត្រា ៩៨៨ (ការសន្មតបិតុភាព) នៃក្រមរដ្ឋប្បវេណី ទារកនៅក្នុងគភ៌របស់អ្នកពពោះជំនួស ដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តីអ្នកពពោះជំនួសនោះ ។ ប៉ុន្តែ ជនដែលត្រូវបានសន្មតថាជាឪពុករបស់កូននោះ មិនអាចប្តឹងបដិសេធបិតុភាពចំពោះកូននោះដោយយកមូលហេតុថា កូននោះកើតមកដោយយកមេជីវិតរបស់អ្នកដាក់ពាក្យសុំ ឬ អ្នកបរិច្ចាគមេជីវិតបានឡើយ ។

**មាត្រា ៤០ --**ករណីយកិច្ចនៃការចុះបញ្ជីកំណើត

បញ្ញត្តិនៃមាត្រា ៩៨៩ (ករណីយកិច្ចនៃការសុំចុះកំណើត) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការចុះបញ្ជីកំណើតរបស់កូនដែលកើតមកពីការពពោះជំនួស ។

# ជំពូកទី ៦
# សុំកូន ដែលកើតមកពីការពពោះជំនួស

**មាត្រា ៤១ --** សុំកូនពេញលេញ

១- អ្នកដាក់ពាក្យសុំពពោះជំនួសដែលជាប្តីនិងប្រពន្ធ ត្រូវដាក់ពាក្យសុំកូនពេញលេញ ក្នុងរយៈពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ និងមិនឲ្យលើសពី ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីកំណើតកូន ។

២- បញ្ញត្តិនៃមាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតស្មុំកូនពេញលេញ) និងមាត្រា ១០១៣ (អំឡុងពេលសាកល្បងចិញ្ចឹម) នៃក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះការស្មុំកូនពេញលេញ ដែលកូននោះកើតមកពីការពពោះជំនួស ។

៣- តុលាការត្រូវពិចារណាទៅលើកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ស្ថានភាពសេដ្ឋកិច្ចរបស់អ្នកដាក់ពាក្យសុំ និងចំណុចចាំបាច់ផ្សេងទៀត ដើម្បីផលប្រយោជន៍របស់កូន មុននឹងសម្រេចបង្កើតស្មុំកូនពេញលេញ ។

**មាត្រា ៤២ –** ស្មុំកូនពេញលេញ ក្នុងករណីសហព័ទ្ធម្ខាង មិនមែនជាជនជាតិខ្មែរ

ក្នុងករណីសហព័ទ្ធម្ខាង នៃអ្នកដាក់ពាក្យសុំពពោះជំនួស មិនមែនជាជនជាតិខ្មែរ ដូចមានចែងនៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣ (លក្ខខណ្ឌរបស់ប្តីប្រពន្ធដែលដាក់ពាក្យសុំ) នៃច្បាប់នេះជននោះ និងសហព័ទ្ធរបស់ជននោះអាចដាក់ពាក្យស្មុំកូនពេញលេញបាន ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤១ (ស្មុំកូនពេញលេញ) នៃច្បាប់នេះ ។

**មាត្រា ៤៣ –** ស្មុំកូនធម្មតា ក្នុងករណីសហព័ទ្ធម្ខាងនៃអ្នកដាក់ពាក្យសុំបានទទួលមរណភាពក្រោយពេលដាក់ពាក្យសុំកូនពេញលេញ

ក្នុងករណីដែលសហព័ទ្ធម្ខាងនៃអ្នកដាក់ពាក្យសុំបានទទួលមរណភាព ក្រោយពេលដាក់ពាក្យសុំកូនពេញលេញ ហើយសហព័ទ្ធដែលនៅរស់ មិនដកពាក្យសុំកូនពេញលេញនោះទេ ពាក្យសុំនោះត្រូវចាត់ទុកថា ជាពាក្យសុំកូនធម្មតា ។

**មាត្រា ៤៤ –** ស្មុំកូនធម្មតា

១- ក្នុងករណីដែលប្តីប្រពន្ធដែលជាអ្នកដាក់ពាក្យសុំពពោះជំនួស លែងលះគ្នា ក្រោយពេលទទួលការអនុញ្ញាតឲ្យពពោះជំនួស ប្តី និងប្រពន្ធនោះត្រូវជ្រើសរើសឲ្យសហព័ទ្ធណាម្ខាងដាក់ពាក្យស្មុំកូនធម្មតា ជាមួយអ្នកពពោះជំនួស និងសហព័ទ្ធរបស់អ្នកពពោះជំនួសនោះ ដែលជាអ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ក្នុងរយៈពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ និងមិនឲ្យលើសពី ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីកំណើតកូន លើកលែងតែប្តីប្រពន្ធនោះរំលាយកិច្ចសន្យា ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៩ (ការរំលាយកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស) នៃច្បាប់នេះ។

២- ក្នុងករណីដែលសហព័ទ្ធម្ខាងនៃអ្នកដាក់ពាក្យសុំពពោះជំនួស បានទទួលមរណភាពក្រោយពេលទទួលការអនុញ្ញាតឲ្យពពោះជំនួស សហព័ទ្ធនៅរស់ ត្រូវដាក់ពាក្យសុំកូនធម្មតាជាមួយអ្នកពពោះជំនួស និងសហព័ទ្ធរបស់អ្នកពពោះជំនួសនោះ ដែលជាអ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ក្នុងរយៈពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ និងមិនឲ្យលើសពី ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីកំណើតកូន លើកលែងតែ សហព័ទ្ធនៅរស់នោះ បានរំលាយកិច្ចសន្យា ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៩ (ការរំលាយកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស) នៃច្បាប់នេះ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះករណីដែលមានចែងនៅក្នុងមាត្រា ៤៣ (សុំកូនធម្មតា ក្នុងករណីសហព័ទ្ធម្ខាងនៃអ្នកដាក់ពាក្យសុំបានទទួលមរណភាព ក្រោយពេលដាក់ពាក្យសុំកូនពេញលេញ) នៃច្បាប់នេះឡើយ ។

**មាត្រា ៤៥ --** នីតិវិធីសម្រេចអំពីសុំកូន

១- សុំកូន ដូចមានចែងចាប់ពីមាត្រា ៤១ (សុំកូនពេញលេញ) ដល់មាត្រា ៤៤ (សុំកូនធម្មតា) នៃច្បាប់នេះ ត្រូវអនុវត្តទៅតាមច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

២- ការសម្រេចអំពីការសុំកូន ដែលកើតមកពីការពពោះជំនួសនេះ តុលាការត្រូវធ្វើការសម្រេចឲ្យបានឆាប់រហ័ស ។

**មាត្រា ៤៦ --** ការចុះបញ្ជី និងការរក្សាការសម្ងាត់នៃសុំកូនដែលកើតមកពីការពពោះជំនួស

១- បញ្ញត្តិនៃមាត្រា ១០១៨ (ការចុះបញ្ជី និងការរក្សាការសម្ងាត់នៃសុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការចុះបញ្ជី និងការរក្សាការសម្ងាត់នៃសុំកូនពេញលេញ ដែលកើតមកពីការពពោះជំនួស ។

២- បញ្ញត្តិនៃមាត្រា ១០៣៣ (ការចុះបញ្ជីនៃសុំកូនធម្មតា និងបញ្ជីកំណើត) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការចុះបញ្ជីនៃសុំកូនធម្មតា ដែលកើតមកពីការពពោះជំនួស ។

**មាត្រា ៤៧ --** សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំដែលកើតមកពីការពពោះជំនួស

១- បញ្ញត្តិនៃមាត្រា ១០១៩ (សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះសិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ ដែលកើតមកពីការពពោះជំនួស ។

២- កូនសុំ ដែលកើតពីការពពោះជំនួស ក្រោយពេលបានក្លាយជានីតិជន អាចទាមទារឲ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស តាមរយៈការិយាល័យទទួលពាក្យសុំបាន ។

## ជំពូកទី ៧

## ការទទួលខុសត្រូវរបស់អ្នកដាក់ពាក្យសុំពពោះជំនួស

**មាត្រា ៤៨ --** បន្ទុកចំណាយរបស់អ្នកដាក់ពាក្យសុំពពោះជំនួស

១- អ្នកដាក់ពាក្យសុំពពោះជំនួស ត្រូវទទួលបន្ទុករាល់ការចំណាយ ដែលបានរៀបរាប់ដូចខាងក្រោម៖

ក- ពន្ធដាក់ពាក្យសុំពពោះជំនួស ។

ខ- សោហ៊ុយចំណាយផ្សេងៗដែលទាក់ទងនឹងការដាក់ពាក្យសុំពពោះជំនួស ។

គ- កម្រៃសេវាបច្ចេកវិទ្យាជំនួយការបង្កកំណើត ។

ឃ- ថ្លៃព្យាបាល ថែទាំសុខុមាលភាពរបស់អ្នកពពោះជំនួស ចាប់តាំងពីដំណាក់កាលដំបូងនៃការពពោះជំនួស រហូតដល់ពេលនីតិវិធីសុំកូនបានបញ្ចប់ ។

ង- ពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធទាក់ទងនឹងសុំកូន ។

ច- ការចំណាយផ្សេងៗទៅលើកូនក្រោយពីបានកើត រហូតដល់ពេលនីតិវិធីនៃការសុំកូនត្រូវបានបញ្ចប់ ។

ឆ- ការចំណាយចាំបាច់ផ្សេងៗទៀត ។

២- ពន្ធដាក់ពាក្យសុំពពោះជំនួស និងសោហ៊ុយចំណាយផ្សេងៗ ដែលទាក់ទងនឹងការដាក់ពាក្យសុំពពោះជំនួស ដូចមានចែងក្នុងកថាខណ្ឌទី ១ ចំណុច ក និង ខ ខាងលើ នឹងត្រូវកំណត់ដោយប្រកាសរួម របស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៩ --** ការទទួលខុសត្រូវ ក្នុងករណីអ្នកដាក់ពាក្យសុំពពោះជំនួស មិនបានដាក់ពាក្យសុំកូន

ក្នុងករណី អ្នកដាក់ពាក្យសុំពពោះជំនួស មិនបានដាក់ពាក្យសុំកូន ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤១ (ស្នុំកូនពេញលេញ) មាត្រា ៤២ (ស្នុំកូនពេញលេញ ក្នុងករណីសហព័ទ្ធម្ខាង មិនមែនជាជនជាតិខ្មែរ) ឬ មាត្រា ៤៤ (ស្នុំកូនធម្មតា) ទេ អ្នកដាក់ពាក្យសុំពពោះជំនួសនោះត្រូវទទួលបន្ទុកសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន និងសោហ៊ុយចំណាយលើការសិក្សារបស់កូនដែលកើតពីការពពោះជំនួសនោះ រហូតដល់កូននោះមាននីតិភាព ។

**មាត្រា ៥០ --** ការទទួលខុសត្រូវ ចំពោះការបំពានកិច្ចសន្យារបស់អ្នកដាក់ពាក្យសុំពពោះជំនួស

ក្រៅពីការទទួលខុសត្រូវ ដែលមានចែងក្នុងមាត្រា ៤៩ (ការទទួលខុសត្រូវក្នុងករណីអ្នកដាក់ពាក្យសុំពពោះជំនួសមិនបានដាក់ពាក្យសុំកូន) នៃច្បាប់នេះ ប្រសិនបើអ្នកដាក់ពាក្យសុំពពោះជំនួសបានបំពានកិច្ចសន្យា អ្នកដាក់ពាក្យសុំពពោះជំនួសនោះ ត្រូវទទួលខុសត្រូវអំពីការបំពាននេះ ចំពោះអ្នកពពោះជំនួស ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៥១ --** អំពើលក់-ដូរ មេជីវិតញី ឈ្មោល ឬ អំប្រីយ៉ុង

១- ជនណាដែលលក់-ដូរ មេជីវិតញី ឈ្មោល ឬ អំប្រីយ៉ុង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ឆ្នាំ ដល់ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

២- នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងនៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៥២ --** ការឲ្យប្រាក់ វត្ថុមានតម្លៃ ឬ ផលប្រយោជន៍ ជាថ្នូរនឹងការពពោះជំនួស

ក្រៅពីការចំណាយ ដូចមានចែងក្នុងមាត្រា ៤៨ (បន្ទុកចំណាយរបស់អ្នកដាក់ពាក្យសុំពពោះជំនួស) នៃច្បាប់នេះ ជនណាដែលបានឲ្យ ប្រាក់ វត្ថុមានតម្លៃ ឬ ផលប្រយោជន៍ផ្សេងទៀត ដើម្បីជាថ្នូរឲ្យស្ត្រីយល់ព្រមពពោះជំនួស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២ (ពីរ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ៥៣ --** អំពើធ្វើជាអន្តរការី

១- ទោះបីមានបញ្ញត្តិនៃមាត្រា ៣៣២ (បទអន្តរការ រវាងអ្នកសុំកូន និងស្ត្រីពពោះ) នៃក្រមព្រហ្មទណ្ឌក៏ដោយ អំពើប្រព្រឹត្តនៅក្នុងគោលបំណង ចង់បានកម្រៃធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬ ប្តីប្រពន្ធ ដែលចង់សុំកូនយកមកចិញ្ចឹម និងស្ត្រីម្នាក់យល់ព្រមពពោះ ដើម្បីនឹងប្រគល់កូននោះឲ្យទៅអ្នកសុំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២ (ពីរ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ ។

២- នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងនៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៥៤ --** ការផ្សព្វផ្សាយជាសាធារណៈ ទាក់ទងនឹងការពពោះជំនួស

១- ជនណា ដែលធ្វើការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មាន សេចក្តីថ្លែងការណ៍ ឯកសារ ឬសម្ភារៈដូចបានរៀបរាប់ខាងក្រោម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២ (ពីរ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ ៖

ក- មានចេតនាទាក់ទាញ បញ្ចុះបញ្ចូល ជនណាមួយឲ្យយល់ព្រមធ្វើជាអ្នកពពោះជំនួស ។

ខ- ស្វែងរក ឬ មានបំណងស្វែងរក ជនណាមួយដែលមានបំណងធ្វើជាអ្នកពពោះជំនួស ។

គ- បញ្ជាក់ ឬ ចង្អុលដោយប្រយោលថា ជនណាមួយមានបំណងយល់ព្រមធ្វើជាអ្នកពពោះជំនួស ។

ឃ- បញ្ជាក់ ឬ ចង្អុលដោយប្រយោលថា ជនណាមួយមានបំណងចូលរួមក្នុងកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ។

២- នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងនៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៥៥ –** ការផ្តល់សេវាពពោះជំនួស ដោយគ្មានឈ្មោះក្នុងបញ្ជី

១- អ្នកវិជ្ជាជីវៈសុខាភិបាល រួមទាំងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ដែលផ្តល់សេវាពពោះជំនួស ដោយគ្មានឈ្មោះនៅក្នុងបញ្ជី ដែលមានចែងនៅក្នុង ចំណុច «ក» កថាខណ្ឌទី ២ នៃមាត្រា ១០ (ការិយាល័យទទួលពាក្យសុំ) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ឆ្នាំ ដល់ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

២- អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ដែលមានឈ្មោះក្នុងបញ្ជី ដែលមានចែងនៅក្នុងចំណុច «ក» កថាខណ្ឌទី ២ នៃមាត្រា ១០ (ការិយាល័យទទួលពាក្យសុំ) នៃច្បាប់នេះ តែបានផ្តល់នូវសេវាពពោះជំនួស នៅកន្លែងដែលមិនមានឈ្មោះនៅក្នុងបញ្ជី ដែលមានចែងនៅក្នុងចំណុច «ខ» កថាខណ្ឌទី ២ នៃមាត្រា ១០ (ការិយាល័យទទួលពាក្យសុំ) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ឆ្នាំ ដល់ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

៣- នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងនៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៥៦ –** ការប្រើបច្ចេកវិទ្យាជំនួយការបង្កកំណើត ដោយពុំទាន់មានការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស

១- ជនណាដែលប្រើបច្ចេកវិទ្យាជំនួយការបង្កកំណើត សម្រាប់ការពពោះជំនួស ដោយពុំទាន់មានការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ខែ ដល់ ០៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

២- នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងនៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៥៧ –** ការផ្តល់សេវា ដើម្បីឲ្យជនដទៃធ្វើអាជីវកម្មពពោះជំនួស

១- ជនណា ដែលផ្តល់សេវាបច្ចេកវិទ្យា វិជ្ជាជីវៈ ឬ សុខាភិបាល ដោយចេតនាទៅឲ្យជនដទៃ ត្រូវផ្តន្ទាទោសពី ០៣ (បី) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ ប្រសិនបើ៖

ក- ដឹងថាជនដទៃនោះជាភាគី ឬ មានបំណងក្លាយជាភាគីនៃកិច្ចសន្យាទាក់ទងនឹងការពពោះជំនួស ដើម្បីធ្វើអាជីវកម្ម និង

ខ- ផ្តល់សេវា ក្នុងគោលបំណងដើម្បីជួយជនដទៃនោះ មានផ្ទៃពោះសម្រាប់គោលបំណងពពោះជំនួស ។

២- នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងនៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការផ្តល់សេវា ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ធ្វើឡើងចំពោះស្ត្រីដែលមានផ្ទៃពោះរួចហើយ ។

**មាត្រា ៥៨ --** អំពើបំពានការប្រើប្រាស់អំប្រីយ៉ុង និងការជ្រើសរើសភេទ

១- ជនណា ដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៤ (ការផ្តល់សេវាកម្មលើបច្ចេកវិទ្យាជំនួយការបង្កកំណើត បម្រើឲ្យការពពោះជំនួស) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ខែ ទៅ ០១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

២- នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងនៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៥៩ --** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

ក្នុងករណីដែលអ្នកតំណាង និយោជិក ឬ បុគ្គលិកដទៃទៀតរបស់នីតិបុគ្គល ព្រមទាំងអ្នកតំណាងដោយអាណត្តិ បានប្រព្រឹត្តនូវអំពើណាមួយដូចមានចែងនៅក្នុងមាត្រា ៥១ (អំពើលក់-ដូរ មេជីវិតញី ឈ្មោល ឬ អំប្រីយ៉ុង) មាត្រា ៥៣ (អំពើធ្វើជាអន្តរការី) មាត្រា ៥៤ (ការផ្សព្វផ្សាយជាសាធារណៈ ទាក់ទងនឹងការពពោះជំនួស) មាត្រា ៥៥ (ការផ្តល់សេវាពពោះជំនួស ដោយគ្មានឈ្មោះក្នុងបញ្ជី) មាត្រា ៥៦ (ការប្រើបច្ចេកវិទ្យាជំនួយការបង្កកំណើត ដោយពុំទាន់មានការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស) មាត្រា ៥៧ (ការផ្តល់សេវា ដើម្បីឲ្យជនដទៃធ្វើអាជីវកម្មពពោះជំនួស) មាត្រា ៥៨ (អំពើបំពានការប្រើប្រាស់អំប្រីយ៉ុង និងការជ្រើសរើសភេទ) ហើយអំពើនោះមានការទាក់ទងទៅនឹងកិច្ចការរបស់នីតិបុគ្គល នីតិបុគ្គលនោះក៏អាចត្រូវបានប្រកាសថា ទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើស ដោយផ្តន្ទាទោសពិន័យជាប្រាក់ចំពោះនីតិបុគ្គល ដូចមានចែងនៅក្នុងមាត្រានីមួយៗខាងលើ ។

**មាត្រា ៦០ --** ទោសបន្ថែមដែលអនុវត្តចំពោះនីតិបុគ្គល

បញ្ញត្តិពីចំណុចទី ៤ រហូតដល់ចំណុចទី ៧ នៃមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិបុគ្គលដែលត្រូវផ្តន្ទាទោសដោយយោងតាមបញ្ញត្តិនៃជំពូកទី ៨ នៃច្បាប់នេះ ។

# ជំពូកទី ៩
# អវសានប្បញ្ញត្តិ

**មាត្រា ៦១ --** អានុភាពនៃបទប្បញ្ញត្តិដែលផ្ទុយនឹងច្បាប់នេះ

បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលច្បាប់នេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថា គ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត ។

**មាត្រា ៦២ --** កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ

ច្បាប់នេះត្រូវអនុវត្តចាប់ពីថ្ងៃទី....... ខែ.......... ឆ្នាំ........ ។